# សេចក្តីថ្លែងការណ៍ពត៌មាន

# មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បញ្ចប់បេសកម្មនៅប្រទេសកម្ពុជា

ភ្នំពេញ ថ្ងៃទី 18 ខែ កញ្ញា ឆ្នាំ 2007

បេសកកម្មមួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិមកពីទីក្រុងវ៉ាស៊ីនតោន ឌីស៊ី បានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ពីថ្ងៃទី 12 ដល់ 18 ខែ កញ្ញា ឆ្នាំ 2007 ដើម្បីពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់នានានៃរាជរដ្ឋាភិបាលកម្ពុជា អំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចថ្មីៗនេះ ព្រមទាំងអំពីគោលនយោបាយនានាផ្នែកសារពើពន្ធ និង ហិរញ្ញវត្ថុ ។ បេសកកម្មក៏បានជួបផងដែរជាមួយតំណាងពីសហគមពាណិជ្ជកម្ម និង ដៃគូរអភិវឌ្ឍន៍នានា។

ការអនុវត្តម៉ាក្រូសេដ្ឋកិច្ចនៅក្នុងឆ្នាំ 2007 នៅតែមានភាពប្រសើរយ៉ាងខ្លាំង។ ផលទុនក្នុងស្រុក(ដុល)គិតជាតំលៃថេរត្រូវបានរំពឹងថានឹងកើនឡើងដល់ប្រមាណ 9½ភាគរយ គាំទ្រដោយការរីកដុះដាលជាបន្តនៃវិស័យកសិកម្ម និង កំនើនយ៉ាងឆាប់រហ័សថែមទៀតនៃវិស័យទេសចរណ៍ ហិរញ្ញវត្ថុ និង សំណង់ ។ ការនាំចេញរបស់វិស័យកាត់ដេរបន្តកើនឡើងយ៉ាងខ្លាំង ទោះបីជាល្បឿននៃកំនើននេះបានសំរួល ដោយសារការកើនឡើងនៃការប្រកួតប្រជែងក្នុងតំបន់ និង ភាពថមថយនៃតំរូវការរបស់ទីផ្សារនាំចេញចំបងនានា ។ កត្តាទាំងអស់នេះទំនងជានឹងនៅតែមានបន្តក្នុងឆ្នាំ 2008 ប៉ុន្តែកំនើនផលទុនក្នុងស្រុកគិតជាតំលៃថេរត្រូវបានព្យាករណ៏ថានៅតែខ្លាំង គឺប្រមាណ 7¾ ភាគរយ ។

អតិផរណាបានកើនឡើងដល់ 6½ភាគរយ ដែលឆ្លុះបញ្ចាំងជាចំបងអំពីការកើនឡើងនៃថ្លៃម្ហូបអាហារ ស្របតាមនិន្នាការក្នុងតំបន់។ ក្នុងខណៈពេលដែលបណ្តាកត្តាខាងក្រៅទាំងនេះបានបង្ហាញជាទូទៅនៃការកើនឡើងនៃអតិផរណារហូតដល់ពេលនេះ បេសកកម្ម និង អាជ្ញាធរបានយល់ស្របគ្នាថា តំរូវអោយមានភាពប្រុងប្រយ័ត្នដើម្បីតាមដានលើមូលដ្ឋាននៃសំពាធអតិផរណាដែលបង្កដោយការកើនឡើងយ៉ាងឆាប់រហ័សនៃតំរូវការក្នុងស្រុក ។

ចំណូលរបស់រដ្ឋាភិបាលបានកើនឡើងយ៉ាងខ្លាំង ឆ្លុះបញ្ចាំងអំពីសកម្មភាពសេដ្ឋកិច្ចដ៏ខ្លាំងក្លា និង គុណប្រយោជន៏ដ៏គួរអោយកត់សំគាល់ដែលទទួលបានពីការពង្រឹងរដ្ឋបាលចំណូល។ ដោយហេតុនេះហើយ អនុបាតចំណូលពន្ធធៀបនឹងផលទុនក្នុងស្រុក (Tax revenue-to-GDP ratio) ត្រូវរំពឹងថានឹងកើនឡើងដល់ប្រមាណ 9½ភាគរយនៅក្នុងឆ្នាំ 2007 ។ ចំណាយត្រូវបានរឹតត្បិត ជាពិសេសចំណាយមូលធន ហើយឱនភាពថវិកាទូទៅរបស់រដ្ឋាភិបាលត្រូវបានរំពឹងថានឹងថយចុះនៅត្រឹម 1½ ភាគរយនៃផលទុនក្នុងស្រុក។

មើលទៅមុខ បេសកកម្មបានស្វាគមន៏ចំពោះគោលបំណងរបស់រដ្ឋាភិបាលក្នុងការបន្តអនុវត្តន៏គោលនយោបាយថវិកាប្រុងប្រយ័ត្នសំរាប់ឆ្នាំក្រោយ។ បេសកកម្មបានបញ្ជាក់ថា ជាមួយនឹងកិច្ចប្រឹងប្រែងផ្នែករដ្ឋបាលជាបន្ថែមទៀត ចំណូលនឹងកែលំអជាបន្ត ផ្តល់លទ្ធភាពក្នុងការបង្កើនចំណាយខ្ពស់ជាងមុនសំរាប់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការចាំបាច់ និង បណ្តាមុខចំណាយជាគន្លឹះសំរាប់ការកាត់បន្ថយភាពក្រីក្រ ដែលស្របតាមផែនការអភិវឌ្ឍន៏យុទ្ធសាស្ត្រជាតិ (NSDP) ។ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានបន្តឈានទៅមុខយ៉ាងល្អប្រសើរ ហើយបេសកកម្មបានស្វាគមន៏ចំពោះកិច្ចប្រឹងប្រែងកំពុងតែមាន ដើម្បីធ្វើវិសោធន៏កម្មលើច្បាប់សារពើពន្ធ ដើម្បីពង្រឹងការយកពន្ធលើវិស័យប្រេង។

វិស័យធនាគារបន្តរីកដុះដាលយ៉ាងលឿន ជាមួយនឹងកំនើននៃប្រាក់បញ្ញើរ និងប្រាក់កំចី ដែលបញ្ជាក់ពីការកើនឡើងនៃការជឿទុកចិត្តមកលើប្រព័ន្ធធនាគារនៃប្រទេសកម្ពុជា។ អាជ្ញាធរបានកំពុងតែពង្រឹងការត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុ ហើយបានយល់ស្រមជាមួយបេសកកម្មថា ការខំប្រឹងប្រែងជាបន្ថែមទៀតនឹងលើកដំកើងភាពជឿទុកចិត្ត ហើយចាំបាច់ណាស់សំរាប់ការពារនូវភាពរឹងមាំរបស់ប្រព័ន្ធហិរញ្ញវត្ថុនេះ។